# «យើងស្វែងរកយុត្តិធម៌សម្រាប់ជនរងគ្រោះ» : សក្ខីកម្មរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា

ដោយ រ៉េនឌល ឌីហ្វាល់កូ

ថ្ងៃទី២៣ ខែមករា ឆ្នាំ២០១២

ប្រែសម្រួលដោយ ជា ផល្លា

កាលពីថ្ងៃច័ន្ទ ទី២៣ ខែមករា ឆ្នាំ២០១២ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាចាប់ផ្តើមសវនាការបន្តទៀត ។ សវនាការថ្ងៃនេះនឹងបង្ហាញពីការធ្វើសក្ខីកម្មរបស់អ្នកតំណាងម្នាក់មកពីមជ្ឈមណ្ឌលឯកសារកម្ពុជា ជាស្ថាប័នស្រាវជ្រាវមួយដែលបានផ្តល់ឯកសារយ៉ាងច្រើនសន្ធឹកសន្ធាប់ដល់សាលាក្តីនេះ ។ ក្រុមការពារក្តីរបស់ជនជាប់ចោទទាំងបីនាក់បានជំទាស់ទៅនឹងការដាក់បញ្ចូលឯកសារទាំងអស់មកពីមជ្ឈមណ្ឌលឯកសារកម្ពុជាដោយយកហេតុផលថា ឯកសារទាំងអស់នោះមិនមានឃថាភាព ហើយមេធាវីរបស់ជនជាប់ចោទបានអះអាងទៀតថា មជ្ឈមណ្ឌលឯកសារកម្ពុជាមិនមែនជាស្ថាប័នអព្យាក្រឹត្យនោះទេ គឺមានភាពលំអៀងទៅខាងព្រះរាជអាជ្ញា ។

## បទអត្ថាធិប្បាយរបស់ នួន ជា ទាក់ទងទៅនឹងសេចក្តីថ្លែងការណ៍របស់នាយករដ្ឋមន្រ្តី ហ៊ុន សែន

គ្រាន់តែអង្គជំនុំជម្រះចាប់ផ្តើមដំណើរការភ្លាម មេធាវីអន្តរជាតិរបស់ នួន ជា ឈ្មោះ ម៉ៃឃើល ផេស្តមែន បានក្រោកឈរឡើង និងសួរដើម្បីសុំបញ្ជាក់នូវអ្វីដែលអង្គជំនុំជម្រះបាននិយាយកាលពីសប្តាហ៍មុន ។ មេធាវីអន្តរជាតិរូបនោះ បានសួរទៅអង្គសវនាការថា តើអ្វីដែលចៅក្រម និល ណុន បាននិយាយកាលពីសប្តាហ៍មុននោះគឺគ្រាន់តែចង់ប្រាប់ថា មេធាវីរបស់ នួន ជា បាននិយាយច្រំដែល ឬក៏ចង់ប្រាប់ឲ្យ“រក្សាភាពអត់ធ្មត់”ទាក់ទងទៅនឹងសេចក្តីសម្រេច ឬមួយជាការសម្រេចពិតប្រាកដ ដែលអង្គជំនុំជម្រះបានដោះស្រាយទាក់ទងនឹងបញ្ហានោះ?

ចៅក្រម ស៊ីលវៀ ខាត់វ្រាយត៍ ដែលបានអវត្តមានពីសវនាការ នៅពេលដែលបញ្ហានេះបានលើកឡើង បានបញ្ជាក់ថា អង្គជំនុំជម្រះនឹងដោះស្រាយបញ្ហានេះ “នៅពេលដ៏សមរម្យណាមួយ” ។ លោកស្រីចៅក្រមបានប្រាប់ទៅ ម៉ៃឃើល ផេស្តមែន ថា “សូមក្រោកឈរ”នៅពេលដែលចង់ឡើងនិយាយ ។

## ការចោទសួរទៅកាន់លោក វ៉ាន់ថាន់ ពៅដារ៉ា មកពីមជ្ឈមណ្ឌលឯកសារកម្ពុជា

អំឡុងពេលសវនាការកាលពីសប្តាហ៍មុន ភាគច្រើន គឺនិយាយអំពីឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា និងពិភាក្សាគ្នាថា តើនាយកមជ្ឈមណ្ឌលឯកសារកម្ពុជា លោក ឆាំង យុ គួរតែមកធ្វើ

សក្ខីកម្មឬក៏អត់? អង្គជំនុំជម្រះបានបញ្ជាក់ថា នរណាក៏ដោយឲ្យតែដឹងច្រើនពីឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជានឹងអាចធ្វើជាសាក្សីបាន ។ អ្នកចូលរួមជាច្រើនចង់ដឹងយ៉ាងខ្លាំងថាតើនរណានឹងត្រូវឡើងមកនិយាយក្នុងសវនាការតំណាងឲ្យមជ្ឈមណ្ឌលឯកសារកម្ពុជា ព្រោះស្ថាប័ននេះបានផ្ដល់ឯកសារជាច្រើនដល់សាលាក្ដីខ្មែរក្រហមមួយនេះ ។ ទីបំផុតអ្នកតំណាងម្នាក់មកពីមជ្ឈមណ្ឌលឯកសារកម្ពុជាចូលក្នុងបន្ទប់សវនាការ ។ លោក វ៉ាន់ថាន់ ពៅដារ៉ា នាយករង និងជាគណៈគ្រប់គ្រងរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។

ដំបូង ចៅក្រម និល ណុន ចាប់ផ្ដើមសួរសំណួរ ។ អំឡុងពេលឆ្លើយទៅនឹងសំណួរដំបូង លោក ដារ៉ា បានបញ្ជាក់ថា លោកធ្វើការនៅមជ្ឈមណ្ឌលឯកសារកម្ពុជាដោយទទួលខុសត្រូវក្នុងការងារជាច្រើនតាំងពីឆ្នាំ១៩៩៥មក ។ ដំបូងលោកចាប់ផ្ដើមធ្វើការជាអ្នកស្ម័គ្រចិត្ត ដែលជាគោលការណ៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។ ក្រោយមក ចៅក្រម យ៉ា សាខន បានចោទសួរនូវសំណួរមួយចំនួនទាក់ទងទៅនឹងរចនាសម្ព័ន្ធ និងតួនាទីរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។ អំឡុងពេលនៃការសាកសួរនេះ លោក ដារ៉ា បានផ្ដល់សក្ខីកម្មថា កិច្ចការរបស់លោកប្រចាំថ្ងៃ គឺទទួលខុសត្រូវការងារទូទៅក្នុងការសម្រេចចិត្តទាក់ទងទៅនឹងកិច្ចការសន្តិសុខ និងកិច្ចការឯកសារនៅមជ្ឈមណ្ឌលឯកសារកម្ពុជា ។ លោក ដារ៉ា បញ្ជាក់ទៀតថា លោកក៏មានភារកិច្ចមើលរៀបចំឯកសារទាំងអស់ដែរ ។ លោកបានរៀបរាប់ពីការប្រមូលឯកសារទាំងអស់នោះ ការចុះលេខឯកសារ និងការថែរក្សាទុកឯកសារ ។ លោក ដារ៉ា បានបន្ថែមទៀតថា លោក«មានភារកិច្ចទាំងស្រុង»ក្នុងការគ្រប់គ្រងកិច្ចការឯកសារទាំងអស់នៅមជ្ឈមណ្ឌលនេះ ។

នៅពេលសួរអំពីតួនាទី និងគោលបំណងរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា លោក ដារ៉ា បានឆ្លើយថា មជ្ឈមណ្ឌលឯកសារកម្ពុជា គឺជាស្ថាប័នឯករាជ្យមួយដែលមានគោលបំណងស្វែងរកការពិតសម្រាប់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងជម្រុញឲ្យមានយុត្តិធម៌សម្រាប់ជនរងគ្រោះពីរបបខ្មែរក្រហម ។ លោកបានបន្ថែមទៀតថា មជ្ឈមណ្ឌលឯកសារកម្ពុជាកើតឡើងដំបូង ជាគម្រោងមួយដែលបង្កើតដោយសាកលវិទ្យាល័យយែល នៅសហរដ្ឋអាមេរិច ។ លោក ដារ៉ា បានបញ្ជាក់ទៀតថា មជ្ឈមណ្ឌលឯកសារកម្ពុជាទទួលបានការអនុញ្ញាតពីរាជរដ្ឋាភិបាលកម្ពុជាដើម្បីធ្វើការស្រាវជ្រាវព័ត៌មានទាំងឡាយដែលទាក់ទងនឹងរបបខ្មែរក្រហមទូទាំងប្រទេសកម្ពុជា រួមទាំងការប្រមូលឯកសារ និងការធ្វើបទសម្ភាសន៍ជាមួយអ្នកដែលធ្លាប់ឆ្លងកាត់ផ្ទាល់ផង ។ នៅពេលសួរអំពី«គោលបំណង»ពិតប្រាកដរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា លោក ដារ៉ា បានឆ្លើយថា លោកបានឆ្លើយនឹងសំណួរនេះរួចហើយ ព្រមទាំងបានបញ្ជាក់ថា មជ្ឈមណ្ឌលឯកសារកម្ពុជាមានគោលដៅចម្បងចំនួនពីរ ។ ទីមួយ គឺដើម្បី«បម្រើ

ដល់ការចងចាំ» នូវអ្វីដែលបានកើតឡើងកាលពីរបបខ្មែរក្រហមពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ និងទីពីរ ដើម្បី«បម្រើដល់សាធារណជនទូទៅ» ដែលចង់«ស្វែងរកយុត្តិធម៌» ។

នៅពេលសួរអំពីប្រភពរបស់ឯកសារទាំងអស់នៅមជ្ឈមណ្ឌលឯកសារកម្ពុជា លោក ដារ៉ា បានឆ្លើយថា មជ្ឈមណ្ឌលឯកសារកម្ពុជាមានគោលនយោបាយរបស់ខ្លួនក្នុងការស្រាវជ្រាវ ហើយមជ្ឈមណ្ឌលឯកសារកម្ពុជាក៏ទទួលបានការអនុញ្ញាតពីរាជរដ្ឋាភិបាលកម្ពុជាក្នុងការស្រាវជ្រាវគ្រប់កន្លែងទាំងអស់ទូទាំងប្រទេស ឬអាចធ្វើការស្រាវជ្រាវនៅបណ្តាប្រទេសផ្សេងៗទៀតផង ។ លោក បញ្ជាក់ទៀតថា មជ្ឈមណ្ឌលឯកសារកម្ពុជាទទួលបានឯកសារពីបុគ្គលនិងស្ថាប័ននានាជាច្រើន តែឯកសារភាគច្រើន គឺប្រមូលដោយមជ្ឈមណ្ឌលឯកសារកម្ពុជាផ្ទាល់ ។

ទាក់ទងទៅនឹងប្រភេទព័ត៌មានដែលបានរក្សាទុកនៅមជ្ឈមណ្ឌលឯកសារកម្ពុជា លោកនាយករងបានបញ្ជាក់ថា មជ្ឈមណ្ឌលឯកសារកម្ពុជាប្រើពាក្យ «ចងក្រងឯកសារ»រាល់ព័ត៌មានទាំងអស់ដែលទាក់ទងទៅនឹងរបបខ្មែរក្រហម ជាពិសេសមជ្ឈមណ្ឌលឯកសារកម្ពុជាចាត់ថ្នាក់ឯកសារទាំងអស់ជា **ប្រាំ** ប្រភេទរួមមាន ៖

១. ឯកសារជាក្រដាស (ប្រហែលជាមួយលានទំព័រ)

២. ការសម្ភាសន៍

៣. រូបថត

៤. ផែនទីរណ្តៅសាកសព និង

៥. ខ្សែភាពយន្ត

សំណួរបន្ទាប់ដែលសួរដោយចៅក្រម គឺទាក់ទងទៅនឹងការបណ្តុះបណ្តាលបុគ្គលិករបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។ លោក ដារ៉ា បានឆ្លើយថា បុគ្គលិករបស់មជ្ឈមណ្ឌលឯកសារកម្ពុជាទទួលបានការបណ្តុះបណ្តាលពីអ្នកជំនាញអន្តរជាតិផ្សេងៗជាច្រើនទាក់ទងទៅនឹងការស្រាវជ្រាវឯកសារ វិធីសាស្ត្រក្នុងការធ្វើសម្ភាសន៍ និងវិធីសាស្ត្រផ្សេងៗទៀត ហើយស្ទើរគ្រប់បុគ្គលិកទាំងអស់ លើកលែងតែបុគ្គលិកសន្តិសុខចេញ សុទ្ធតែចេះនិងធ្លាប់ប្រមូលឯកសារ ព្រមទាំងធ្វើបទសម្ភាសន៍ទាំងអស់ ។

ទាក់ទងទៅនឹងប្រភពឯកសារ លោក ដារ៉ា បានបញ្ជាក់ថា មជ្ឈមណ្ឌលឯកសារកម្ពុជា ទទួលបានឯកសារពីប្រភពផ្សេងៗ ចាប់ពីរដ្ឋាភិបាលដល់បុគ្គលផ្សេងៗ ។ លោកបានពន្យល់ថា នៅពេលដែលមជ្ឈមណ្ឌលឯកសារកម្ពុជាទទួលបានឯកសារនីមួយៗ ដំបូងត្រូវថតចម្លងទុកសិន ក្រោយមកទើបចុះលេខឯកសារនោះ រួចយកឯកសារទាំងនោះទៅទុកនៅកន្លែងសុវត្ថិភាព ។ ក្រោយពីទុកនៅកន្លែងសុវត្ថិភាពរួចហើយ ឯកសារថតចម្លងនីមួយៗអាចប្រើប្រាស់នៅក្នុងមជ្ឈមណ្ឌលឯកសារកម្ពុជា

បានដោយមិនចែកចាយទៅសាធារណជនទូទៅទេ ការធ្វើបែបនេះ គឺដើម្បីថែរក្សាបូរណភាពរបស់ឯកសារដើម ។

ទាក់ទងទៅនឹងវិធីសាស្រ្តសម្ភាសន៍ លោក ដារ៉ា បានគូសបញ្ជាក់ថា មជ្ឈមណ្ឌលឯកសារកម្ពុជាមិនប្រើពាក្យ "សាក្សី" ទេ តែប្រើប្រាស់ឯកសាររបស់ខ្លួនដើម្បីផ្ទៀងផ្ទាត់ រួចធ្វើការសម្ភាសន៍មនុស្សមួយចំនួនដែលទាក់ទងជាមួយនឹងឯកសារនោះ ។ មជ្ឈមណ្ឌលឯកសារកម្ពុជាបានស្វែងរកអ្នកដែលត្រូវធ្វើសម្ភាសន៍នៅជនបទ និងកសាងទំនាក់ទំនងជាមួយអ្នកដែលធ្វើសម្ភាសន៍នោះផ្ទាល់ ព្រមទាំងអាជ្ញាធរដែនដី ។ លើសពីនោះទៅទៀត អ្នកដែលបានសម្ភាសន៍នោះតែងកំណត់ពីអត្តសញ្ញាណអ្នកផ្សេងទៀតដើម្បីធ្វើសម្ភាសន៍ ។

រាល់ការធ្វើសម្ភាសន៍ម្តងៗ បុគ្គលិករបស់មជ្ឈមណ្ឌលឯកសារកម្ពុជាត្រូវធានាថា អ្នកនោះអាចឈប់ផ្តល់បទសម្ភាសន៍ពេលណាក៏បាន ហើយការធ្វើសម្ភាសន៍នោះគ្មានការបង្ខិតបង្ខំអ្វីទេ ។ លោក ដារ៉ា បានបញ្ជាក់ទៀតថា មជ្ឈមណ្ឌលឯកសារកម្ពុជាក៏មិនបានជូនជាថវិការដល់អ្នកដែលបានផ្តល់បទសម្ភាសន៍ទេ មានតែពាក្យថា "អរគុណ"ប៉ុណ្ណោះ ដល់អ្នកទាំងនោះដែលបានផ្តល់ការសម្ភាសន៍ និងចែករំលែកនូវបទពិសោធន៍ផ្ទាល់ខ្លួន ។

លោក ដារ៉ា បានឆ្លើយទៅនឹងសំណួរផ្សេងទៀតថាមជ្ឈមណ្ឌលឯកសារកម្ពុជាទទួលយកឯកសារទាំងអស់រួមទាំងឯកសារដើមនិងឯកសារថតចម្លង តែឯកសារទាំងអស់ត្រូវបញ្ជាក់ពីយថាភាព ។ មជ្ឈមណ្ឌលឯកសារកម្ពុជាពិនិត្យមើលទាំងការប្រើប្រាស់ពាក្យពេចន៍ និងភាសាដែលបានសរសេរនៅក្នុងឯកសារទាំងនោះ ។ លោកបានបន្តទៀតថា បើតាមលោកចាំ មជ្ឈមណ្ឌលឯកសារកម្ពុជាធ្លាប់បានជំទាស់ទៅនឹងឯកសារមួយទាក់ទងទៅនឹងការចាប់ជម្រិតអ្នកទេសចរចំនួនពីររូប ។ លោក ដារ៉ា បញ្ជាក់ទៀតថា មជ្ឈមណ្ឌលឯកសារកម្ពុជាជំទាស់ទៅនឹងឯកសារនោះ ព្រោះខ្លឹមសារដែលបានរៀបរាប់នៅក្នុងឯកសារនោះមិនស៊ីគ្នាទៅនឹងភាសារបស់ខ្មែរក្រហម ។ ដើម្បីសុវត្ថិភាពរបស់ឯកសារ ដារ៉ា បានបញ្ជាក់ថា រាល់ឯកសារដើមទាំងអស់ត្រូវបានរក្សាទុកនៅក្នុងទូដែលដុតមិនឆេះ និងទឹកន្លែងដែលមានការគ្រប់គ្រងសីតុណ្ហភាពត្រឹមត្រូវ ។

ចំពោះអំពីព័ត៌មានផ្សេងទៀតអំពីដំណាក់កាលនៃការសម្ភាសន៍ លោក ដារ៉ា បានបញ្ជាក់ថា បុគ្គលិករបស់មជ្ឈមណ្ឌលឯកសារកម្ពុជាតែងធ្វើដំណើរទៅតាមខេត្តនានាជាក្រុម ដោយក្នុងមួយក្រុមមានសមាជិកចាប់ពី ពីរទៅបីនាក់ដើម្បីធ្វើសម្ភាសន៍ ។ រាល់សម្ភាសន៍ទាំងអស់ត្រូវបានថតជាសម្លេង រួចចម្លងចេញពីកាសែ្សត រួចរក្សាទុកឯកសារទាំងនោះតាមប្រភេទនៃបទសម្ភាសន៍នោះ ។ អត្ថបទដែល

បានចម្លងចេញ ពីការស្វែរតនោះត្រូវបានរក្សាទុកជាមួយឯកសារផ្សេងទៀតដែលប្រមូលដោយបុគ្គលិករបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។

ទាក់ទងទៅនឹងទស្សនាវដ្តីទង់បដិវត្តន៍ និងទស្សនាវដ្តីយុវជនបដិវត្តន៍ លោកបានបញ្ជាក់ថា មជ្ឈមណ្ឌលឯកសារកម្ពុជាបានប្រមូលទស្សនាវដ្តីជាច្រើនច្បាប់ តែគាត់មិនដឹងថាខ្មែរក្រហមបានបោះពុម្ពទស្សនាវដ្តីអ្វីខ្លះទេ ហើយខាងមជ្ឈមណ្ឌលឯកសារកម្ពុជាបានថតចម្លងគ្រប់លេខទាំងអស់របស់ទស្សនាវដ្តី ដែលបោះពុម្ពដោយខ្មែរក្រហមដើម្បីកុំឲ្យមានការប៉ះពាល់ដល់ឯកសារដើម ។

ទាក់ទងទៅនឹងប្រភពរបស់ឯកសារទាំងនេះ លោកបានបញ្ជាក់ថា ឯកសារថតចម្លងជាច្រើនរបស់ខ្មែរ គឺជាកម្មសិទ្ធរបស់ប្រជាជនដែលបានត្រលប់មកកាន់លំនៅដ្ឋានវិញក្រោយថ្ងៃ៧ មករា ឆ្នាំ១៩៧៩ ហើយប្រជាជនទាំងនោះរកឃើញឯកសារទាំងនោះនៅក្នុងផ្ទះដែលធ្លាប់ប្រើប្រាស់ដោយកម្មាភិបាលខ្មែរក្រហម ។

ចៅក្រម ហ្សង់ម៉ាក ឡាវើញ បានឡើងសួរអំពីកាលបរិច្ឆេទក្នុងការបង្កើតមជ្ឈមណ្ឌលឯកសារកម្ពុជា ។ ប្រហែលជាមកពីបញ្ហាក្នុងការបកប្រែជាភាសាបារាំងដែលបានអះអាងថា មជ្ឈមណ្ឌលឯកសារកម្ពុជាបានបង្កើតឡើងក្នុងឆ្នាំ១៩៥៥ មិនមែនឆ្នាំ១៩៩៥ទេនោះ ។ ចំណុចនេះធ្វើឲ្យមានការភាន់ច្រឡំរវាងចៅក្រម និងលោក ដារ៉ា ហើយទោះបីជាចៅក្រមសុំបញ្ជាក់ជាច្រើនលើកច្រើនសារហើយក៏ដោយ ក៏ចម្លើយនៅតែឆ្លើយថាឆ្នាំ១៩៥៥ដដែល ។

ទោះបីជាមានការលំបាកបែបនេះក៏ដោយ ចៅក្រម ឡាវើញ បន្តសំណួរបន្ទាប់ទាក់ទងទៅនឹងការបង្កើតរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាតាមផ្លូវច្បាប់ និងសួរអំពីភាពឯករាជ្យពីសាកលវិទ្យាល័យយែល ។ លោក ដារ៉ា បានតបថា គម្រោងរបស់សាកលវិទ្យាល័យយែលបានបញ្ចប់នៅក្នុងឆ្នាំ១៩៩៧ គឺពីរឆ្នាំក្រោយពីមជ្ឈមណ្ឌលឯកសារកម្ពុជាត្រូវបានបង្កើតឡើង ។ ចាប់ពីឆ្នាំ១៩៩៧មកមជ្ឈមណ្ឌលឯកសារកម្ពុជា នៅតែបន្តកិច្ចការទៅមុខទៀតក្នុងនាមជាអង្គការក្រៅរដ្ឋាភិបាលឯករាជ្យមួយ ។ លោកបានបញ្ជាក់ទៀតថា គោលបំណងនិងបេសកម្មរបស់មជ្ឈមណ្ឌលឯកសារកម្ពុជានៅតែដដែល ក្រោយពីមជ្ឈមណ្ឌលឯកសារកម្ពុជាស្រាវជ្រាវដោយឯករាជ្យ ។

ចំពោះផ្នែកហិរញ្ញវត្ថុរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា លោក ដារ៉ា បានបញ្ជាក់ថា លោកមិនមានដែនសមត្ថកិច្ចក្នុងការពិភាក្សាពីបញ្ហានេះទេព្រោះគាត់ផ្តោតទៅលើតែកិច្ចការឯកសារប៉ុណ្ណោះ ។

ទាក់ទងទៅនឹងកិច្ចការគម្រោងស្រាវជ្រាវនៅមជ្ឈមណ្ឌលឯកសារកម្ពុជាទាំងអស់ លោកបានបញ្ជាក់ថា មជ្ឈមណ្ឌលឯកសារកម្ពុជាមានគម្រោងផ្សេងៗជាច្រើនដែលគម្រោងនីមួយៗមានប្រធានក្រុមម្នាក់ ។ នៅពេលសួរអំពី«គម្រោងស្រាវជ្រាវរណ្តៅសាកសព» នៅក្នុងប្រទេសកម្ពុជា លោក ដារ៉ា

បានឆ្លើយថា គម្រោងនេះចាប់ដំណើរការតាំងពីឆ្នាំ១៩៩៥មកម៉្លេះ តែក្នុងរយៈពេលពីរបីឆ្នាំចុងក្រោយនេះ គម្រោងនេះហាក់បីដូចជាបន្ថយសកម្មភាពបន្តិច ។

លោកបានបន្តទៀតថា គម្រោងសំខាន់ៗផ្សេងទៀតរបស់មជ្ឈមណ្ឌលឯកសារកម្ពុជារួមមានគម្រោងសម្ភាសន៍ជាមួយអតីតកម្មាភិបាលខ្មែរក្រហម គម្រោងផ្សព្វផ្សាយពីកិច្ចការរបស់មជ្ឈមណ្ឌលគម្រោងបង្រៀនគ្រូអំពីប្រវត្តិសាស្ត្រខ្មែរក្រហម គម្រោងសម្ភាសន៍ផ្ទាល់មាត់ គម្រោងបោះពុម្ពទស្សនាវដ្ដី «ស្វែងរកការពិត» និងគម្រោងផ្សេងៗទៀត ។

ឆ្លើយតបទៅនឹងសំណួរក្រោយមកទៀត លោក ដារ៉ា បានបញ្ជាក់ថា មជ្ឈមណ្ឌលឯកសារកម្ពុជាបានផ្ដល់ឯកសារទាំងអស់ដោយឥតគិតថ្លៃដល់សាធារណជនក្នុងការស្រាវជ្រាវ និងគ្មានការរិតត្បិតក្នុងការប្រើប្រាស់ឯកសារទាំងនោះទេ ។

## អៀង សារី និង នួន ជា ហត់នឿយ មិនអាចបន្តអង្គុយនៅក្នុងបន្ទប់សវនាការបាន

ពេលអង្គជំនុំជម្រះហៀបនឹងប្រកាសសម្រាកនៅពេលព្រឹកនេះ មេធាវីរបស់ អៀង សារី បានជូនដំណឹងទៅអង្គជំនុំជម្រះថា អៀង សារី ចង់សុំសិទ្ធមិននៅក្នុងបន្ទប់សវនាការ និងសុំទៅតាមដានក្នុងបន្ទប់រង់ចាំវិញ ។ សំណើនេះត្រូវបានយល់ព្រមដោយអង្គជំនុំជម្រះ ហើយក៏បានណែនាំឲ្យមេធាវីរបស់ អៀង សារី ប្រគល់លិខិតជាលាយលក្ខណ៍អក្សរទាក់ទងនឹងការស្នើសុំនេះមកកាន់អង្គជំនុំជម្រះ ។

បន្ទាប់ពីសម្រាក នួន ជា បានធ្វើសំណើរទៅសម្រាកក្នុងបន្ទប់រង់ចាំ ។ សំណើរនេះក៏ទទួលការយល់ព្រមពីអង្គជំនុំជម្រះផងដែរ ។

## ការចោទសួរទៅកាន់លោក វ៉ាន់ថាន់ ពៅដារ៉ា បន្តទៀត

ក្រោយពីសម្រាក និងសំណើរបស់ អៀង សារី និង នួន ជា រួចមក លោក វ៉ាន់ថាន់ ពៅដារ៉ា បានបន្តឆ្លើយសំណួររបស់ចៅក្រម ឡាវើញ ។ ក្រោយពីចោទសួររួច លោក ដារ៉ា បានបញ្ជាក់ថា មជ្ឈមណ្ឌលឯកសារកម្ពុជាផ្ទុកទៅដោយឯកសារដើមផងនិងឯកសារថតចម្លងផង ។ ឯកសារទាំងនោះរួមមាន របាយការណ៍ ឯកសារដែលសរសេរឡើងមុននិងក្រោយរបបខ្មែរក្រហម ។ លោកបានបន្ថែមទៀតថា មជ្ឈមណ្ឌលឯកសារកម្ពុជាមិនឲ្យតម្លៃទៅលើឯកសារណាមួយនោះទេ គឺឯកសារទាំងអស់សុទ្ធតែសំខាន់ ។ លោកបានបញ្ជាក់ទៀតថា ឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជាមានឯកសារជាច្រើនដែលសរសេរឡើងក្រៅពីភាសាខ្មែរ ជាមួយគ្នានោះមជ្ឈមណ្ឌលឯកសារកម្ពុជាបានបកប្រែឯកសារមួយចំនួន ។ មជ្ឈមណ្ឌលឯកសារកម្ពុជាផ្ដល់ជូនអ្នកស្រាវជ្រាវផ្សេងៗ នូវឯកសារជាភាសាបរទេស ហើយអ្នកស្រាវជ្រាវទាំងនោះជាអ្នកបកប្រែដោយខ្លួនឯង ។ ទាក់ទងទៅនឹងការចុះ

ប្រភេទឯកសារ លោកបានបញ្ជាក់ថា រាល់ប្រភេទឯកសារទាំងអស់ត្រូវបានកត់ត្រាទុកនៅក្នុងបញ្ជី ដូចជាឯកសារខ្លះផ្ដើមដោយអក្សរ“D” ។ លោក ដារ៉ា បានបញ្ជាក់ទៀតថា ការដាក់លេខកូដឯកសារនេះមិនមានការប្រែប្រួលទេ ព្រោះលេខកូដនោះមិនត្រូវបានសរសេរលើឯកសារដើមទេ ។ ម៉្យាងវិញទៀត មជ្ឈមណ្ឌលឯកសារកម្ពុជាមិនបានចារនៅលើឯកសារណាមួយទេ មានតែឯកសារថតចម្លងទេទើបអាចផ្ដល់ជូនដល់អ្នកស្រាវជ្រាវបាន ។ ការធ្វើបែបនេះដើម្បីឲ្យដឹងថា ឯកសារដើមមិនមានការប្រែប្រួលទេ ។

ទាក់ទិននឹងឯកសារដែលមានប្រភពមកពីបណ្ណសារដ្ឋានជាតិ លោក ដារ៉ា បានបញ្ជាក់ថា មជ្ឈមណ្ឌលឯកសារកម្ពុជា បានថតចម្លងឯកសារទាំងអស់ពីបណ្ណសារដ្ឋានជាតិ ដែលទាក់ទងទៅនឹងរបបខ្មែរក្រហមព្រមទាំងមានការអនុញ្ញាតពីរដ្ឋាភិបាលកម្ពុជា ដូច្នេះមជ្ឈមណ្ឌលឯកសារកម្ពុជាអាចចូលទៅស្រាវជ្រាវឯកសារទាំងអស់ ដែលទាក់ទងទៅនឹងរបបខ្មែរក្រហមក្នុងស្ថាប័នរបស់រដ្ឋាភិបាលទាំងឡាយ ហើយឯកសារទាំងនោះត្រូវបានរក្សាទុកដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ។

ក្រោយមក លោក ដារ៉ា បានពិភាក្សាអំពីឯកសារដែលទទួលបានពីបុគ្គលផ្សេងៗ ។ លោកបានឲ្យដឹងថា នៅពេលដែលបុគ្គលិករបស់មជ្ឈមណ្ឌលឯកសារកម្ពុជាចុះទៅធ្វើការស្រាវជ្រាវក្នុងទីកន្លែងណាមួយ ជួនកាលបុគ្គលមួយចំនួនផ្ដល់ឯកសារមកមជ្ឈមណ្ឌលឯកសារកម្ពុជា ។ មជ្ឈមណ្ឌលឯកសារកម្ពុជាបានត្រួតពិនិត្យនិងផ្ទៀងផ្ទាត់រាល់ឯកសារទាំងអស់ ចុះកំណត់ហេតុដោយដាក់ឈ្មោះ ទីកន្លែង និងកាលបរិច្ឆេទ រួចទុកឯកសារនោះក្នុងកន្លែងសុវត្ថិភាព ។

នៅពេលសួរថា តើមជ្ឈមណ្ឌលឯកសារកម្ពុជាអាចកំណត់ថា ឯកសារនោះជាឯកសារពិតឬទេ បើសិនជាមិនមានប្រភពត្រឹមត្រូវនោះ? លោក ដារ៉ា បានឆ្លើយថា មជ្ឈមណ្ឌលឯកសារកម្ពុជាបានសួរទៅអ្នកដែលផ្ដល់ឯកសារនោះអំពីប្រភពនិងកាលបរិច្ឆេទរបស់ឯកសារ ព្រមទាំងបានបញ្ជាក់ថា អង្គជំនុំជម្រះអាចសួរទៅអ្នកសរសេរឯកសារនោះបានបើសិនជាអាច ។

ទាក់ទងទៅនឹងឯកសារ“ស៊ុយអែត”របស់មជ្ឈមណ្ឌលឯកសារកម្ពុជា លោក ដារ៉ា បញ្ជាក់ថា មជ្ឈមណ្ឌលឯកសារកម្ពុជាទទួលបាននិងចុះបញ្ជីឯកសារទាំងអស់នោះ តែមជ្ឈមណ្ឌលឯកសារកម្ពុជាមិនមានអ្នកជំនាញជាភាសាស៊ុយអ៊ែតទេ ។

នៅពេលសួរអំពីប្រភពរបស់ឯកសារផ្សេងទៀត ដូចជាឯកសារមកពីបណ្ណសាររបស់បារាំង លោកបានឆ្លើយថា ឯកសារទាំងអស់ដែលបានប្រគល់ជូនមជ្ឈមណ្ឌលឯកសារកម្ពុជាត្រូវបានត្រួតពិនិត្យ ចុះបញ្ជី និងរក្សាទុក ហើយថា ឯកសារទាំងអស់ត្រូវបានធ្វើកិច្ចការទាំងអស់នេះ ។

ចំពោះឯកសារផ្ទាល់ខ្លួនរបស់អតីតព្រះមហាក្សត្រ នរោត្តម សីហនុ លោក ដាវ៉ា បានបញ្ជាក់ថា ឯកសារទាំងអស់នេះអាចរកបានក្នុងគេហទំព័ររបស់ព្រះអង្គផ្ទាល់ តែគេហទំព័រនេះមិនដំណើរការទេសព្វថ្ងៃនេះ ។ លោកបន្តទៀតថា រដ្ឋាភិបាលបានអនុញ្ញាតឲ្យមជ្ឈមណ្ឌលឯកសារកម្ពុជាចុះស្រាវជ្រាវរាល់បណ្ណសាររបស់រដ្ឋាភិបាលទាំងអស់ រួមទាំងបណ្ណសាររបស់គណបក្សប្រជាជនកម្ពុជាផង ។

នៅពេលសួរអំពីការស៊ើបអង្កេតបទឧក្រិដ្ឋ ដែលធ្វើឡើងដោយវៀតណាមក្នុងសម័យសាធារណរដ្ឋប្រជាមានិតកម្ពុជា លោក ដាវ៉ា បានបញ្ជាក់ថា អ្នកជំនាញការវៀតណាមបានជួយក្នុងការប្រមូលឯកសារកាលពីទសវត្សរ៍៨០ ដូចជាបណ្ណសារដែលតម្កល់ទុកនៅគុកទួលស្លែងជាដើម ហើយខាងមជ្ឈមណ្ឌលឯកសារកម្ពុជា ក៏ទទួលបានភាពយន្តឯកសារខ្លះពីអង្គាធរវៀតណាម ទាក់ទងទៅនឹងរបបខ្មែរក្រហមផងដែរ ។

ទាក់ទងទៅនឹងឯកសារមកពីប្រទេសផ្សេងទៀត លោក ដាវ៉ា បានពន្យល់ថា មជ្ឈមណ្ឌលឯកសារកម្ពុជាបានអំពាវនាវដល់សាធារណជនទូទៅដើម្បីសុំឯកសារពីបណ្ដាប្រទេសផ្សេងៗ ហើយមជ្ឈមណ្ឌលឯកសារកម្ពុជាក៏ទទួលបានឯកសារមួយចំនួនដែរពីអ្នកស្រាវជ្រាវ និងសាស្ត្រាចារ្យមួយចំនួន ដូចជា សាស្ត្រាចារ្យ ឡូ៉វ៉ាំសាំម៉េ ជាដើម ។ លោកបានបញ្ជាក់ដែរថា លោកធ្លាប់ទទួលបានរូបថតទាក់ទងនឹងរបបខ្មែរក្រហមមួយចំនួនពីបុគ្គលផ្ទាល់ខ្លួន ។

បន្ទាប់មក ចៅក្រម ឡាវ៉ឺញ បានសួរទាក់ទងទៅនឹងទំនាក់ទំនងរវាងមជ្ឈមណ្ឌលឯកសារកម្ពុជា និងការិយាល័យសហព្រះរាជអាជ្ញារបស់អង្គជំនុំជម្រះ ។ លោក ដាវ៉ា បានបញ្ជាក់ថា មជ្ឈមណ្ឌលឯកសារកម្ពុជាធ្វើការជាមួយ «ស្ទើរគ្រប់ការិយាល័យ និងស្ថាប័នទាំងអស់របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានេះ មិនមែនតែជាមួយការិយាល័យសហព្រះរាជអាជ្ញា» ប៉ុណ្ណោះទេ ។ លោកបានពន្យល់ថា ឯកសារនឹងផ្តល់ជូនដល់អង្គជំនុំជម្រះបើសិនជាមានសំណើ ព្រមទាំងផ្តល់ជូនដោយឥតគិតថ្លៃ និងដោយគ្មានកំណត់ ។

ក្រោយមក អង្គជំនុំជម្រះប្រកាសសម្រាកអាហារថ្ងៃត្រង់ ។

ក្រោយពីសម្រាក ចៅក្រម និល ណុន បានរំឭកឡើងវិញទៅគ្រប់ភាគីទាំងអស់ថា រាល់ពេលសួរសំណួរ គ្រប់អ្នកសួរទាំងអស់ត្រូវតែក្រោកឈរ ដោយលោកចៅក្រមបានបញ្ជាក់ថា ប្រការនេះត្រូវបានអនុវត្តទូទៅនៅក្នុងប្រព័ន្ធច្បាប់ក្នុងប្រទេសកម្ពុជា ។ ក្នុងករណីស្នើសុំដោយប្រការណាមួយ អង្គជំនុំជម្រះអាចលើកលែងបាន ។ ក្រោយមក ចៅក្រម ឡាវ៉ឺញ បន្តសួរសំណួរទៅកាន់លោក ដាវ៉ា បន្តទៀតទាក់ទងទៅនឹងភ័ស្តុតាងដែលតុលាការស្នើពីមជ្ឈមណ្ឌលឯកសារកម្ពុជា ។

ចៅក្រម ឡាវីញ បានសួរទៅ លោក ដារ៉ា អំពីចម្លើយសារភាពដែលទទួលបានពីគុកទួលស្លែង ដែលផ្តល់ជូនមកអង្គជំនុំជម្រះដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ។ លោក ដារ៉ា បានអះអាងថា គាត់ជាអ្នកផ្តល់ឯកសារទាំងនោះមកអង្គជំនុំជម្រះ ហើយឯកសារនោះគឺជាគម្របខាងក្រៅរបស់ចម្លើយសារភាព ដែលមានចំណារនៅពីលើនោះដោយរដ្ឋមន្ត្រីក្រសួងការពារជាតិរបស់កម្ពុជាប្រជាធិបតេយ្យឈ្មោះ សុន សេន ។ លោកបានបញ្ជាក់ទៀតថា លេខនៅលើឯកសារនោះមិនមែនជាលេខកូដរបស់មជ្ឈមណ្ឌលឯកសារទេ ព្រោះរូបនោះ គឺជារូបដែលថតចេញពីឯកសារដើម ហើយបើសិនជាឯកសារចម្លង អាចមានលេខកូដរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។ ចំពោះចំណារនៅលើឯកសារនោះ លោក ដារ៉ា បាននិយាយថា ទឹកប៊ិចនៅលើគម្របនោះ គឺជាទឹកប៊ិចចាស់ ហើយនៅក្នុងចម្លើយសារភាពខ្លះ ឈ្មោះរបស់អ្នកទោសដែលចារនៅលើចម្លើយសារភាពនោះ ឃើញមាននៅលើចម្លើយសារភាពនោះ ។ លោក ដារ៉ា បានឲ្យដឹងថា ទោះបីជាមិនមានឈ្មោះនៅលើឯកសារនោះក៏ដោយ ក៏លោកនៅចាំដែរថា ចំណារនោះគឺជាចំណាររបស់ សុន សេន ។ ក្រោយមក លោក ដារ៉ា បានអានចំណារនោះឮៗ ហើយនិយាយថា លោកជាអ្នកចងក្រងឯកសារនេះដោយផ្ទាល់ ហើយបើតាមគំនិតរបស់លោក ចំណារនៅលើចម្លើយសារភាព ព្រោះធ្វើឡើងដោយ សុន សេន តែម្នាក់ប៉ុណ្ណោះ ។

ក្រោយមក ចៅក្រម បានបង្ហាញឯកសារមួយទៀតទៅលោក ដោយមានចំណារនៅពីលើឯកសារនោះផង ។ លោក ដារ៉ា បានបញ្ជាក់ថា លោកបានអានឯកសារនោះរួចហើយនៅមជ្ឈមណ្ឌលឯកសារកម្ពុជា ហើយថា ចំណារនោះចារដោយ “ខៀវ” ។ ក្រោយមក លោកបានបញ្ជាក់ថា ពាក្យ “សម្ងាត់បំផុត” ត្រូវបានគូសបន្ទាត់នៅក្នុងឯកសារនោះ ហើយថាការធ្វើបែបនេះព្រោះឯកសារនោះ “ទាក់ទងជាមួយនិងភូមិភាគបូព៌ា” ។ ចំណារនៅលើឯកសារនោះចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ១៩៧៧ ហើយលោកបាននិយាយថា ឈ្មោះ “ខៀវ” គឺជាឈ្មោះរបស់ សុន សេន ។ ចៅក្រម ឡាវីញ បានបញ្ចប់នៅពេលនេះ ហើយពេញមួយរសៀលទៀត ចៅក្រម ឡាវីញ មិនបានសួរសំណួរទៀតទេ ។

## ព្រះរាជអាជ្ញាសួរសំណួរទៅ វ៉ាន់ថាន់ ពៅដារ៉ា

សហព្រះរាជអាជ្ញាអន្តរជាតិ ថារិក អាប់ឌុលហាក់ ចាប់ផ្តើមសួរសំណួរ ។ សំណួរទីមួយដែលបានចោទសួរទៅ លោក ដារ៉ា គឺទាក់ទងទៅនឹងកម្រិតវប្បធម៌ ។ លោកបានឆ្លើយថា គាត់ទទួលបានសញ្ញាប័ត្រច្បាប់ពីសាកលវិទ្យាល័យភូមិន្ទនិតិសាស្ត្រក្នុងទីក្រុងភ្នំពេញ និងទទួលបានសញ្ញាបត្រអនុបណ្ឌិតផ្នែកសិទ្ធិមនុស្ស និងច្បាប់ពីសាកលវិទ្យាល័យណ័រត្រឺខេមសហរដ្ឋអាមេរិក ។ លោកទទួលបានការ

បណ្តុះបណ្តាលផ្នែកឯកសារ និងការស៊ើបអង្កេតពីសាកលវិទ្យាល័យញូសៅវែល ប្រទេសអូស្ត្រាលី និងពីប្រទេសអៀរឡង់ ។

លោកបានបញ្ជាក់ទៀតថា ជាធម្មតាម្ចាស់ជំនួយដែលជួយផ្នែកហិរញ្ញវត្ថុដល់មជ្ឈមណ្ឌលឯកសារកម្ពុជាមានលក្ខខ័ណ្ឌអ្វីទេ ហើយមជ្ឈមណ្ឌលឯកសារកម្ពុជាធ្វើការដោយឯករាជ្យ ។ លោក ដារ៉ា បានបញ្ជាក់ផងដែរថា មជ្ឈមណ្ឌលឯកសារកម្ពុជាមិនទទួលបានជំនួយបុច្ចវិការណាមួយពីរដ្ឋាភិបាលកម្ពុជាទេ លើកលែងតែការអនុញ្ញាតក្នុងការស្រាវជ្រាវ និង«ការណែនាំ»ផ្សេងៗប៉ុណ្ណោះ ។

ក្រោយពីបកស្រាយជាច្រើនចំណុចផ្នែករដ្ឋបាល និងរចនាសម្ព័ន្ធបុគ្គលិករបស់មជ្ឈមណ្ឌលឯកសារកម្ពុជារួចមក ។ លោក ដារ៉ា ត្រូវសួរសំណួរផ្សេងទៀតអំពីដំណើរការនៃការសម្ភាសន៍ ។ លោកបានពន្យល់ថា ការសម្ភាសន៍ភាគច្រើនត្រូវបានធ្វើឡើងដោយគម្រោង«ដាក់ឲ្យមានការទទួលខុសត្រូវ» របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ហើយថា បុគ្គលិករបស់មជ្ឈមណ្ឌលឯកសារកម្ពុជាធ្វើការសម្ភាសន៍អតីតកម្មាភិបាលខ្មែរក្រហមផង និងជនរងគ្រោះផង ហើយរាល់សំណួរទាំងអស់ត្រូវបានកំណត់ដោយទីប្រឹក្សាច្បាប់របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។ លោកបានបញ្ជាក់ទៀតថា មជ្ឈមណ្ឌលឯកសារកម្ពុជាធ្វើការសម្ភាសន៍ជាមួយអតីតកម្មាភិបាលខ្មែរក្រហមផង និងជនរងគ្រោះផង ព្រោះគោលបំណងរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា គឺដើម្បីចងក្រងប្រវត្តិសាស្ត្ររបបកម្ពុជាប្រជាធិបតេយ្យ និងបានបោះពុម្ពសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ហើយគោលបំណង គឺប្រមូលគ្រប់ព័ត៌មានទាំងអស់ទាក់ទងនឹងរបបខ្មែរក្រហម ។

ទាក់ទងទៅនឹងអត្ថបទបោះពុម្ពផ្សាយ លោក ដារ៉ា បានបញ្ជាក់ថា មជ្ឈមណ្ឌលឯកសារកម្ពុជាបានបោះពុម្ពផ្សាយទស្សនាវដ្ដី "ស្វែងរកការពិត" ប្រចាំខែរបស់ខ្លួន និងឯកសារផ្សេងទៀតទាក់ទងនឹងប្រវត្តិសាស្ត្រខ្មែរក្រហម ។ លោកបាននិយាយថា មជ្ឈមណ្ឌលឯកសារកម្ពុជាមាន«កិច្ចការចម្បង»ក្នុងការបណ្តុះបណ្តាលគ្រូប្រវត្តិសាស្ត្រអំពីប្រវត្តិសាស្ត្រខ្មែរក្រហម និងដើម្បីស្វែងរកការបង្រួបបង្រួមជាតិក្នុងប្រទេសកម្ពុជា ។

ក្រោយពីសំណួរបន្តទៀត លោក ដារ៉ា បានបញ្ជាក់ថា គម្រោងស្រាវជ្រាវពីរណ្តៅសាកសពរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា បានចុះទៅស្រាវស្រាវគ្រប់ស្រុកទាំង១៨៦ តែមិនបានគូសផែនទីទីកន្លែងទាំងអស់ដែលជាអតីតរបស់តំបន់ខ្មែរក្រហមទេ ហើយរហូតមកដល់ពេលនេះ តំបន់ខ្មែរក្រហមទាំងនោះមិនទាន់មានការស្រាវជ្រាវពីរណ្តៅសាកសពនៅឡើយទេ ។ លោកបានបញ្ជាក់ថា ដំបូងមជ្ឈមណ្ឌលឯកសារកម្ពុជារកមើលកន្លែងទីតាំងរណ្តៅសាកសព ដោយប្រើប្រាស់ឯកសារដែលបានប្រមូលទុក និងតាមរយៈទិន្នន័យដែលទទួលបានពីរដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតកម្ពុជា តាមរយៈពាក្យ

បណ្ដឹងរបស់អ្នកធ្លាប់ឆ្លងកាត់របបនោះ និងតាមរយៈឯកសារឃោសនារបស់ខ្មែរក្រហម ។ លោក ដាវ៉ា បានបញ្ជាក់ទៀតថា មជ្ឈមណ្ឌលឯកសារកម្ពុជា ត្រូវបានចង្អុលប្រាប់ពីសំណាក់អ្នកភូមិដែលធ្លាប់ជីករណ្ដៅសាកសព កាលពីក្រោយឆ្នាំ១៩៧៩ ។ ក្នុងការកត់ត្រាពីទីតាំងនីមួយៗ លោកបានឲ្យដឹងថា មជ្ឈមណ្ឌលឯកសារកម្ពុជា បានប្រើប្រាស់ឧបករណ៍កំណត់ទីតាំងភូមិសាស្ត្រ ដើម្បីកំណត់ពីរយៈកំពស់ និងរយៈបណ្ដោយរបស់ទីតាំងរណ្ដៅសាកសពនីមួយៗ ។ លទ្ធផលនៃការស្រាវជ្រាវនោះគឺ ផ្សព្វផ្សាយនៅលើគេហទំព័ររបស់មជ្ឈមណ្ឌលឯកសារកម្ពុជាផងដែរ ។

នៅពេលសួរអំពីជោគវាសនារបស់ឯកសារដើមខ្មែរក្រហម ក្រោយពីការរលំរលាយរបស់រាជរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យក្នុងខែមករា ឆ្នាំ១៩៧៩ លោក ដាវ៉ា បានបញ្ជាក់ថា ឯកសារខ្មែរក្រហមនៅរាយពាសពេញទាំងអស់ទូទាំងប្រទេសកម្ពុជា អំឡុងពេលនៃការប្រយុទ្ធគ្នារវាងទ័ពខ្មែរក្រហម និងទាហានវៀតណាម ។ លោកបានបន្ថែមទៀតថា មានឯកសារខ្លះដាច់ដោចមិនគ្រប់គ្រាន់ ហើយមជ្ឈមណ្ឌលឯកសារកម្ពុជាមានតែផ្នែកខ្លះប៉ុណ្ណោះ ។

ទាក់ទងទៅនឹងប្រភពឯកសារ លោក ដាវ៉ា បានបញ្ជាក់ថា ឯកសារជាច្រើនក្រៅពីឯកសារចម្លើយសារភាពត្រូវបានរកឃើញនៅគុកទួលស្លែង ហើយបុគ្គលិករបស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានប្រមូលឯកសារទាំងអស់នោះ និងលោកជាអ្នកត្រួតពិនិត្យមើលឯកសារទាំងអស់នៅគុកទួលស្លែង ។ លោកបានឲ្យដឹងទៀតថា គុកទួលស្លែង ត្រូវបានប្ដូរទៅជាសារមន្ទីរ ក្រោយពីការដួលរលំនៃរបបខ្មែរក្រហម ហើយឯកសារទាំងអស់ត្រូវបានរកឃើញនៅទីនោះរាយពាសពេញ រហូតដល់ពេលដែលមជ្ឈមណ្ឌលឯកសារកម្ពុជាទៅប្រមូលនៅទីនោះ ។

ក្រោយមកព្រះរាជអាជ្ញាបានងាកទៅសួរអំពីឯកសារដែលយកមកពីក្រសួងមហាផ្ទៃ ។ លោក ដាវ៉ា បានបញ្ជាក់ថា ឯកសារទាំងនេះរួមមាន ចម្លើយសារភាព ឯកសារ លន់ នល់ និងឯកសារផ្សេងៗទៀត ។ លោកបានបន្ថែមទៀតថា បើតាមលោកដឹង ឯកសារទាំងនេះត្រូវបានប្រមូលទុកដោយរដ្ឋាភិបាលកម្ពុជា ហើយឯកសារដើមត្រូវបានប្រគល់ជូនទៅមជ្ឈមណ្ឌលឯកសារកម្ពុជា ។

នៅពេលសួរថា ហេតុអ្វីបានជាមានឯកសារដើមរបស់ចម្លើយសារភាពនិងឯកសារផ្សេងៗមាននៅទួលស្លែងផង និងបណ្ណសារដ្ឋានជាតិផង លោក ដាវ៉ា បានឆ្លើយថា លោកជឿថាឯកសារមួយចំនួនត្រូវបានបញ្ជូនពីទួលស្លែងទៅកាន់ក្រសួងការពារជាតិរបស់កម្ពុជាប្រជាធិបតេយ្យ ក្រោមបញ្ជារបស់ សុន សេន ដូច្នេះឯកសារថតចម្លង និងឯកសារបញ្ជូន ត្រូវបានរកឃើញនៅមានកន្លែងផ្សេងទៀត ។

ក្រោយមក ព្រះរាជអាជ្ញាសួរអំពីឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ដូចជាឯកសារសន្តិបាល និងឯកសារ លន់ នល់ ហើយលោកបានពន្យល់អំពីវិធីសាស្ត្រក្នុងការចងក្រងឯកសារ និងការ

ចុះបញ្ជីឯកសារ ។ នៅពេលសួរអំពីការស្រាវជ្រាវដោយ ដាវីដ ហក របស់បេសកកម្មស្រាវជ្រាវឯកសារកម្ពុជា លោក ដារ៉ា បានបញ្ជាក់ថា ឯកសារមួយចំនួនដែលប្រមូលបាន គឺជាកិច្ចខំប្រឹងប្រែងរបស់ ដាវីដ ហក ដែលក្រោយមកបានប្រគល់ជូនដល់មជ្ឈមណ្ឌលឯកសារកម្ពុជា ហើយឯកសារនោះរួមមាន ឯកសារ“D” ។ ឯកសារទាំងនេះយកមកពីអ្នកស្រាវជ្រាវនានាដូចជា ដាវីដ ហក និងសាស្ត្រាចារ្យ បេន គៀរនិន ជាដើម ហើយសព្វថ្ងៃឯកសារនេះត្រូវរក្សាទុកនៅមជ្ឈមណ្ឌលឯកសារកម្ពុជា ។

លោក ដារ៉ា ក៏បានបញ្ជាក់ដែរថា ក្រៅពី ដាវីដ ហក និង សាស្ត្រាចារ្យ បែន គៀរនិន លោកសាស្ត្រាចារ្យ ដេវីដ ឆេនដ៏ល័រ ក៏បានផ្តល់ឯកសារមួយចំនួនដល់មជ្ឈមណ្ឌលឯកសារកម្ពុជាផងដែរ ។ លោកបានឲ្យដឹងទៀតថា ក្រោយពីទទួលបានឯកសារទាំងអស់នោះ មជ្ឈមណ្ឌលឯកសារកម្ពុជាបានសួរសំណួរទៅអ្នកដែលផ្តល់ជូននូវឯកសារដើម បញ្ជាក់ពីយថាភាពរបស់ឯកសារទាំងអស់នោះ ។ ក្រៅពីនោះ ឯកសារទាំងអស់ ត្រូវបានត្រួតពិនិត្យដើម្បីបញ្ជាក់ពីយថាភាពតាមគោលការណ៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។ លោក ដារ៉ា បានបន្ថែមទៀតថា តាមបទពិសោធន៍ធ្វើការនៅមជ្ឈមណ្ឌលឯកសារកម្ពុជាចំនួន១៧ឆ្នាំកន្លងមក លោកបានដឹងបានពីឯកសារណាជាឯកសារពិត និងឯកសារណាជាឯកសារក្លែងក្លាយ ហើយលោកក៏អាចកំណត់ ពីយថាភាពរបស់ឯកសារខ្មែរក្រហមបាន ។

ក្រោយមក ព្រះរាជអាជ្ញាបានបង្ហាញសំណុំឯកសារមួយចំនួនដែលទទួលបានពីមជ្ឈមណ្ឌលឯកសារកម្ពុជាដើម្បីបង្ហាញជូន លោក ដារ៉ា ។ ទីមួយគឺឯកសារពីមជ្ឈមណ្ឌលឯកសារកម្ពុជាគឺឯកសារ“D” ។ លោក ដារ៉ា បានបញ្ជាក់ថា ឯកសារត្រូវបានកំណត់លេខយោងតាមប្រព័ន្ធចុះបញ្ជី ។ លេខដែលមាននៅលើឯកសារនោះត្រូវបានប្រើប្រាស់ ដើម្បីកំណត់ពីទីតាំងនៃឯកសារដើមនៅក្នុងបណ្ណសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។ ព្រះរាជអាជ្ញាបានបញ្ជាក់ថា ដោយបង្ហាញពីគេហទំព័ររបស់មជ្ឈមណ្ឌលឯកសារកម្ពុជាថា ឯកសារអាចរកបានដោយត្រឹមត្រូវ ដោយសារចុះលេខ“D01648” ។ លោក ដារ៉ា បានប្រាប់ពីឯកសារផ្សេងទៀត នៅពេលដែលសួរដោយព្រះរាជអាជ្ញាក្រោយមក ។ ឯកសារទាំងនេះរួមមាន ឯកសារដែលប្រមូលពីគុកទួលស្លែង និងកូនសៀវភៅទង់បដិវត្តន៍ ។ លោកបានពន្យល់ថា ទស្សនាវដ្តី“ទង់បដិវត្តន៍” ត្រូវបានផ្តល់ជូនទៅមជ្ឈមណ្ឌលឯកសារកម្ពុជាពីប្រជាជនដែលបានរកឃើញទស្សនាវដ្តីនេះនៅក្នុងផ្ទះក្រោយពីផ្ទះនោះត្រូវបោះបង់ចោលក្នុងរបបខ្មែរក្រហម ។

ក្រោយពីការបង្ហាញពីឯកសារមួយចំនួន ព្រះរាជអាជ្ញាបានសួរសំណួរអំពីកិច្ចការមួយចំនួនដែលធ្វើឡើងដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ទាក់ទងទៅនឹងកិច្ចដំណើរការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ មជ្ឈមណ្ឌលឯកសារកម្ពុជាបានជួយភាគីដើមបណ្តឹងរដ្ឋប្បវេណី និងមេធាវី ។ លោកបាននិយាយថា មជ្ឈមណ្ឌលឯកសារកម្ពុជាបានផ្តល់ឯកសារជាច្រើន ទាក់ទងទៅនិងសាច់ញាតិរបស់

ដើម្បីបណ្តឹងរដ្ឋប្បវេណីទាំងនោះ ដើម្បីជួយក្នុងការដាក់ពាក្យបណ្តឹង ។ មជ្ឈមណ្ឌលឯកសារកម្ពុជាបាន ជួយគ្រប់ភាគីទាំងអស់របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។

នៅពេលសួរអំពីការដែលមានការចោទប្រកាន់ថា កិច្ចការរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាមានភាពលំអៀង លោក ដារ៉ា បានបញ្ជាក់ម្តងហើយម្តងទៀតថា គោលបំណងចម្បងរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាគឺ ដើម្បីការចងចាំ និងការចងក្រងឯកសារនូវអ្វីដែលបានកើតឡើងក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ក្នុងគោលបំណងស្វែងរកយុត្តិធម៌ ។ មជ្ឈមណ្ឌលឯកសារកម្ពុជាបានផ្តល់ឯកសារទៅគ្រប់ភាគីទាំងអស់ដោយគ្មានប្រកាន់អ្វីឡើយ ។ លោកបានបញ្ជាក់ទៀតថា មជ្ឈមណ្ឌលឯកសារកម្ពុជាមិន «ធ្វើការវិភាគ» ឯកសាររបស់ខ្លួនទេ តែមជ្ឈមណ្ឌលឯកសារកម្ពុជាគ្រាន់តែចុះបញ្ជីឯកសារទាំងនោះនិងផ្តល់ឯកសារថតចម្លងទៅគ្រប់ភាគីដែលបានស្នើសុំ ។

ដល់ចំណុចនេះ អង្គជំនុំជម្រះបានប្រកាសបញ្ចប់កិច្ចដំណើរការសម្រាប់ថ្ងៃនេះ ហើយនឹងបន្តសវនាការនៅថ្ងៃអង្គារ ហើយលោកនាយករងមជ្ឈមណ្ឌលឯកសារកម្ពុជានិងឡើងធ្វើសក្ខីកម្មបន្តទៀតទាក់ទងទៅនឹងឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។

**- ចប់ -**